ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១២

# ដំណឹងជ្រើសរើសបុគ្គលិក

**អង្គការរ៉ាយស្មាត អន្តរជាតិ** ជាអង្គការជាតិ មានគោលបំណងចូលរួមអភិវឌ្ឍវិស័យអប់រំថ្នាក់មូលដ្ឋាន និងកម្មវិធីជួយខ្លួនឯង ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការផ្តល់ឱកាសទទួលបានឥណទានរបស់ប្រជាពលរដ្ឋដែលមានចំណូលទាប និងជាពិសេសសម្រាប់និស្សិតដើម្បីបង្កើតភាពជោគជ័យក្នុងការរៀនសូត្រ ការប្រកបមុខរបរនិងការងារ។

**អង្គការរ៉ាយស្មាត អន្តរជាតិ** ឥឡូវ ត្រូវការជ្រើសរើសបុគ្គលិក ជា**មន្រ្តីឥណទាន**ចំនួន**៣នាក់**បន្ថែមទៀតតាមការរីកចម្រើនរបស់គម្រោងនៃកម្មវិធីជួយខ្លួនឯង។

**លក្ខណសម្បត្តិដែលត្រូវមាន៖**

- មានបទពិសោធន៍ការងារជាបុគ្គលិកឬ មន្រ្តីឥណទាន យ៉ាងតិច១ឆ្នាំ
- មានសញ្ញាប័ត្របរិញ្ញាប័ត្រ
- ភេទប្រុស
- មានអត្តចរិកល្អ សុចរិតទៀងត្រង់ សុភាពរៀបសារនិងការតាំងចិត្តស្រឡាញ់ការងារ
- មានសមត្ថភាពធ្វើទំនាក់ទំនងល្អ និងការដោះស្រាយបញ្ហាជាមួយប្រជាពលរដ្ឋគ្រប់ប្រភេទ

**ការងារដែលត្រូវធ្វើ៖**

- ជួបជាមួយប្រជាពលរដ្ឋ ដើម្បីស្វែងយល់នូវការខ្វះខាត ស្ថានភាពគ្រួសារនិងតម្រូវការថវិការបស់គាត់ ក្នុងការប្រកបមុខរបរឬធ្វើការងារផ្សេងៗ។
- ចូលរួមជាមួយសហគមន៍ដើម្បីដោះស្រាយបញ្ហានានាដោយផ្ទាល់។
- តាមដានគម្រោងជាប្រចាំ។
- បំពេញការងារដោយយកចិត្តទុកដាក់តាមគោលការណ៍របស់អង្គការ។
- និងការងារផ្សេងៗទៀតតាមតួនាទីនិងតម្រូវការរបស់អង្គការ។

បេក្ខជនដែលមានចំណាប់អារម្មណ៍ សូមដាក់CVនិងពាក្យសុំការងារមកការិយាល័យ **អង្គការរ៉ាយស្មាតអន្តរជាតិ** ដែលមានអាស័យដ្ឋានផ្ទះលេខ5DE0 ផ្លូវលេខ450 សង្កាត់ទួលទំពូង២ខណ្ឌចំការមន រាល់ម៉ោងធ្វើការ ចាប់ពីពេលជូនដំណឹងនេះ **រហូតដល់ថ្ងៃទី១២ខែមករាឆ្នាំ២០១៣ ត្រឹមម៉ោង២រសៀល**។ ហើយការប្រកាសបញ្ជីឈ្មោះបេក្ខជនshortlistដើម្បីធ្វើកិច្ចសម្ភាសន៍និងប្រលងខ្លី នឹងជូនដំណឹងនៅថ្ងៃទី១៦ខែមករាឆ្នាំ២០១៣វេលាម៉ោង១០ព្រឹកនៅការិយាល័យរបស់អង្គការ។
អានពត៌មានបន្ថែមនៅ www.rightssmart.com។